# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

ប្រ.ក/លេខ ១២.១៧៣/០៨ គ.ជ.ប.អគ្គ.៣ស

ភ្នំពេញ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៨

## សន្និសីទសារព័ត៌មាន ផ្សព្វផ្សាយប្រតិទិន និងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឆ្នាំ ២០០៩

នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានរៀបចំសន្និសីទសារព័ត៌មានមួយ ដើម្បីផ្សព្វផ្សាយប្រតិទិនការងារ និងសេចក្តីព្រាងបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដល់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតជាច្រើនទៀត ។

ឯកឧត្តម អ៊ឹម សូស្ដី ប្រធាន គ.ជ.ប បានមានប្រសាសន៍ថា ដើម្បីឱ្យសេចក្តីព្រាងនេះធានាបានទាំងខ្លឹមសារស្របតាមបញ្ញត្តិច្បាប់ និងឆ្លើយតបទៅនឹងតម្រូវការ និងការអនុវត្តជាក់ស្តែង គ.ជ.ប ស្នើសុំភាគីពាក់ព័ន្ធទាំងអស់ពិនិត្យផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ និងផ្ញើមក គ.ជ.ប វិញ យ៉ាងយូរត្រឹមថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០៩ ខាងមុខនេះ ។

ឯកឧត្តមបានបញ្ជាក់ថា ការបោះឆ្នោតនេះ ជាការបោះឆ្នោតអសកល ហើយមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ១១.៣៥៣ នាក់ ដែលកំពុងបំរើការនៅតាមឃុំ សង្កាត់ ទូទាំង ១.៦២១ ជាអ្នកបោះឆ្នោត ។ ការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅថ្ងៃ អាទិត្យ ទី ១៧ ខែ ឧសភា ឆ្នាំ ២០០៩ ។

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ៤ ចែងថា ភ្នំពេញជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា ។ រាជធានីភ្នំពេញចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់ ។ មាត្រា ៥ ចែងថា ខេត្តចែកជាក្រុង និងជាស្រុក ហើយក្រុងចែកជាសង្កាត់ ស្រុកចែកជាឃុំ និងជាសង្កាត់ ។

ឯកឧត្តម អ៊ឹម សូស្ដី បានបន្ថែមថា ការិយាល័យបោះឆ្នោតត្រូវបានកំណត់យកក្រុង ស្រុក ខណ្ឌ គឺជាការិយាល័យបោះឆ្នោត ហើយចំនួនសមាជិកក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។ ចំពោះបេក្ខជនដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា បេក្ខជនម្នាក់ៗនៃគណបក្សនយោបាយអាចឈរឈ្មោះជាបេក្ខជននៅមណ្ឌលបោះឆ្នោតណាមួយក៏បាន ឱ្យតែគោរពតាមលក្ខខណ្ឌនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ។ ឯកឧត្តមបានបន្តថា ក្រុងចំនួន ៣ ត្រូវបានប្តូរឈ្មោះទៅជាខេត្ត គឺក្រុងព្រះសីហនុទៅជាខេត្តព្រះសីហនុ ក្រុងប៉ៃលិនទៅជាខេត្តប៉ៃលិន និងក្រុងកែបទៅជាខេត្តកែប ។

សន្និសីទសារព័ត៌មាននេះ មានការចូលរួមពីតំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ សរុបប្រមាណ ៤០ នាក់ ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ E-mail: necinfo@forum.org.kh, Web-site: www.necelect.org.kh